| ៧- | អនុសេនីយ៍ឯក | គង់ | វាសនា | ០១៦០៨៣ | ជំនួយការផ្នែកលេខា ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក |
| ៨- | អនុសេនីយ៍ទោ | ខៃ | ធារី | ១៩៦១៥៣ | ជំនួយការផ្នែកលេខា ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក |
| ៩- | អនុសេនីយ៍ទោ | ពិន | ថិរៈ | ០៣៥១៦៨ | មេរង ខ កងការពារ កងពលតូចអន្តរាគមន៍លេខ១៤ |
| ១០- | អនុសេនីយ៍ត្រី | ខួន | បុត្រា | ២១៩៧១៣ | ជំនួយការផ្នែកលេខា ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក |
| ១១- | អនុសេនីយ៍ត្រី | ឡុច | សុខា | ០៣៦៧៥២ | ជំនួយការផ្នែកលេខា ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក |
| ១២- | ព្រិន្ទបាលឯក | ខេង | ថៃសាង | ២០៦៤៩១ | នាយក្រុមតម្រួតការពារមណ្ឌលអភិវឌ្ឍន៍ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១២៦.១.អនក្រ-ធប**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ១៩ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តពោធិដ្ឋាន** ស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោកជំទាវ អ៊ូ **សារឿន** សប្បុរសជននៅរាជធានីភ្នំពេញ
២-ឧបាសក **ម៉ុន ហ៊ាង** សប្បុរសជននៅខេត្តព្រៃវែង
៣- ឧបាសក **ព្រាប ហ៊ីន** សប្បុរសជននៅខេត្តព្រៃវែង
៤-ឧបាសក **នូ ថន** សប្បុរសជននៅខេត្តព្រៃវែង
៥-ឧបាសក **ចាន់ យ៉ឹន** សប្បុរសជននៅខេត្តព្រៃវែង
៦-ឧបាសិកា **ហង្ស យ៉ឹម** សប្បុរសជននៅខេត្តព្រៃវែង
៧-ឧបាសក **គោត ម៉ៅ** សប្បុរសជននៅខេត្តព្រៃវែង
៨-ឧបាសក **ស៊ិន ណុល** សប្បុរសជននៅខេត្តព្រៃវែង
៩-ឧបាសក **ពិន អ៊ុល** សប្បុរសជននៅខេត្តព្រៃវែង

១០-ឧបាសក នួច សារឿន សប្បុរសជននៅខេត្តព្រៃវែង

១១-ឧបាសិកា អន ហ៊ុន សប្បុរសជននៅខេត្តព្រៃវែង

១២-ឧបាសិកា ទ៉ា សំបុក សប្បុរសជននៅខេត្តព្រៃវែង

១៣-ឧបាសិកា ឡុង យឿន សប្បុរសជននៅខេត្តព្រៃវែង

១៤-ឧបាសិកា ទៃ ឡេង សប្បុរសជននៅខេត្តព្រៃវែង

១៥-ឧបាសិកា ហួត ម៉ិច សប្បុរសជននៅខេត្តព្រៃវែង

១៦-ឧបាសិកា យ៉េន ស៊ន់ សប្បុរសជននៅខេត្តព្រៃវែង

១៧-ឧបាសិកា អ៊ាង ឈួន សប្បុរសជននៅខេត្តព្រៃវែង

១៨-លោក ក្លួត សុវណ្ណា សប្បុរសជននៅរាជធានីភ្នំពេញ

១៩-លោក ហ៊ឿង ខេមរុណ សប្បុរសជននៅខេត្តស្ទឹងត្រែង

**មាត្រា២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤២៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .‒**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីជាការ និងសប្បុរជនចំនួន ០៤ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តពោធិដ្ឋាន** ស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក~ មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន០៣ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **ឈាង ផល្លី** ព្រះចៅអធិការវត្តពោធិដ្ឋាន

២-លោកអនុសេនីយ៍ឯក **ម៉ុន សត្យា** នាយផ្នែកជួញដូរមនុស្ស និងអនីតិជន អគ្គស្នងការនគរបាលជាតិ

៣-លោកអនុសេនីយ៍ត្រី **លៀវ ខេង** មន្ត្រីនគរបាលរាជធានីភ្នំពេញ

**ខ~ មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០១ គ្រឿង ផ្តល់ជូន**

លោកអនុសេនីយ៍ត្រី **គង់ ស៊ីណាត** មន្ត្រីនគរបាលរាជធានីភ្នំពេញ

**មាត្រា ២ .‒**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៧៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ០២ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តពោធិដ្ឋាន** ស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោកអនុសេនីយ៍ត្រី **នូ មន** មន្ត្រីនគរបាលនាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ

២-លោកអនុសេនីយ៍ត្រី **ឡាច វណ្ណនី** មន្ត្រីនគរបាលនាយកដ្ឋានព្រំដែនទឹក ក្រសួងមហាផ្ទៃ

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ២០ រូប ដែលបានលះបង់កំលាំងកាយចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៣ គ្រឿង ផ្តល់ជូន :**

១-លោក **សៅ ប្រសិទ្ធ** អភិបាល នៃគណៈអភិបាលស្រុកពាមរក៍

២-លោក **ម៉ៃ ម៉េង** អភិបាលរង នៃគណៈអភិបាលស្រុកពាមរក៍

៣-លោកស្រី **សេង ឡៀង** អភិបាលរង នៃគណៈអភិបាលស្រុកពាមរក៍

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០៨ គ្រឿង ផ្តល់ជូន :**

១-លោកអនុសេនីយ៍ឯក **អ៊ុន សុផានណារិទ្ធ** អធិការរងនគរបាលស្រុកពាមរក៍

២-លោកអនុសេនីយ៍ឯក **ឡុង ស៊ីថា** នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៣-លោកអនុសេនីយ៍ឯក **ស៊ូ រីណា** នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៤-លោកអនុសេនីយ៍ទោ ផាន់ ចំនួនភោសី មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកពាមរក៍

៥-លោកអនុសេនីយ៍ទោ អ៊ី រតនា មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកពាមរក៍

៦-លោកអនុសេនីយ៍ទោ ឡុង សុខហេង នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

៧-លោកអនុសេនីយ៍ទោ សាន់ ធារិទ្ធ នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៨-លោក ឈិន សារ៉ាត សមាជិកក្រុមប្រឹក្សាស្រុកពាមរក៍

គ-មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០៩ គ្រឿង ផ្តល់ជូន :

១-លោក ឡៅ ឆែម មេឃុំព្រែកព្រៀង

២-លោក ចៅ នន់ មេឃុំបាបោង

៣-លោក ជូ ស៊ីផាត មេឃុំពាមមានជ័យ

៤-លោក ឈិន សេងហាក់ អនុប្រធានការិយាល័យសង្គមកិច្ចស្រុកពាមរក៍

៥-លោក មាស ស៊ុនហាក់ ប្រធានមណ្ឌលសុខភាពស្រុកពាមរក៍

៦-លោក ហ៊ិន សារី នាយសង្កាត់រដ្ឋបាលជលផលពាមរក៍

៧-លោក ហ៊ឹម សារ៉េត មេភូមិលេខ៤ ឃុំព្រែកខ្សាយ ខ

៨-លោកអនុសេនីយ៍ឯក មាស ញ៉ា ជំនួយការស្នាក់ខេត្ត ការិយាល័យទី២ កងទ័ពជើងគោក

៧-លោកអនុសេនីយ៍ទោ សាន់ ធារិទ្ធ នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង

៩-លោក ពុធ ស្រេង ប្រធានគ្រូតពិនិត្យចលនាការិយាល័យពេទ្យសត្វខេត្តព្រៃវែង

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់**មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ១៥ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក | **ជា សុខា** | ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជនស្រុកពាមរក៍ |
| ២-លោក | **ឈួន ពិសី** | អនុប្រធានការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុសាលាស្រុកពាមរក៍ |
| ៣-លោកស្រី | **មាស ស៊ីធឿន** | អនុប្រធានការិយាល័យគាំទ្រឃុំ សង្កាត់សាលាស្រុកពាមរក៍ |
| ៤-លោក | **ឡេង ហៃ** | មេភូមិលេខ៥ ឃុំព្រែកខ្សាយ "ខ" |
| ៥-លោក | **លឹម ជួន** | មេភូមិលេខ២ ឃុំព្រែកខ្សាយ "ខ" |
| ៦-លោក | **ស៊ឹម សារួន** | ស្មៀនឃុំពាមមានជ័យ |
| ៧-លោក | **សេង តាង** | ស្មៀនឃុំអ្នកលឿង |
| ៨-លោក | **អ៊ុន សារឹម** | ស្មៀនឃុំព្រែកខ្សាយ "ក" |
| ៩-លោក | **ខែន ស្រ៊ុន** | ប្រធានការិយាល័យប្រជាពលរដ្ឋ |
| ១០-លោក | **ឃឹម ហៀង** | មន្ត្រីស្នាក់ការពន្ធដាស្រុកពាមរក៍ |

១១-លោកអនុសេនីយ៍ឯក **រឹម សារិទ្ធ** មេបញ្ជាការរងកងរាជអាវុធហត្ថស្រុក

១២-លោកអនុសេនីយ៍ត្រី **ទួន សំអឿន** នាយរងផ្នែក នៃអធិការដ្ឋាននគរបាលស្រុកពាមរក៍

១៣-លោកអនុសេនីយ៍ត្រី **រស់ សុវត្ថា** នាយរងផ្នែក នៃអធិការដ្ឋាននគរបាលស្រុកពាមរក៍

១៤-លោកអនុសេនីយ៍ត្រី **ដួង សែ** មន្ត្រីកងរាជអាវុធហត្ថស្រុកពាមរក៍

១៥-លោកព្រិន្ទបាលទោ **ទៅ សារឿន** មន្ត្រីនគរបាលខេត្តព្រៃវែង

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៧៦៦.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាម៉ាអាហាត់ដារិស្សលាម ទិញដីសាងសង់សាលា និងធ្វើរបង ស្ថិតនៅក្នុងឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

១- លោក ហាជីម៉ូហាំម៉ាត់ ឈ្មពិនអាប់ឌុលការធៀត សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

២- លោក ហាជីអាពូធាកា ពិនម៉ូហាំម៉ាត់យូសុះ សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

៣- លោក ហាជីម៉ូហាំម៉ាត់ណាជីប ពិនហាជីអះម៉ាត់ សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

៤- លោក ហាជីរៃធម៉ាន ពិនអាប់ឌុលណាជីប សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

៥- លោក ហាជីម៉ូហាំម៉ាត់ ពិនហាជីអះម៉ាត់ សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

៦- លោក អូសស្តាសហ្វាន្ទី ពិនអ៊ីស្មាអ៊ែល សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

៧- លោក អូសស្តាសហ្សកាវីយ៉ា ពិនអាម៉ាច់ សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ១១.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១- លោក អូសស្តាសអូម៉ៅ ពិនហូស៊េន សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ៥.១០០ ដុល្លារ

២- លោក អូសស្តាសហ្សកាវីយ៉ា ពិនអាប់ឌុលឡោះ សប្បុរសជនជនជាតិម៉ាឡេស៊ី ថវិកា ៥.១០០ ដុល្លារ

៣- លោក ហ្សកាវីយ៉ា ពិនម៉ូហាំម៉ាត់ស៊េន សប្បុរសជននៅខេត្តកំពង់ចាម ថវិកា ៥.១០០ ដុល្លារ

៤- លោក ភូប យ៉ា សប្បុរសជននៅខេត្តកំពង់ចាម ថវិកា ៥.០៥០ ដុល្លារ

៥- លោក **ហាជីរំលី ពិនម៉ូហាំម៉ាត់សើន** សប្បុរសជននៅខេត្តកំពង់ចាម ថវិកា ៥.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧៦៧ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយ នាយរងនិងពលនគរបាលនៃការិយាល័យគ្រប់គ្រងបច្ចេកទេសការពារ ចំនួន០៩រូប ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មនិងទទួលបានលទ្ធផលល្អប្រសើរក្នុងការបំពេញភារកិច្ចការពារ សន្តិសុខ សុវត្ថិភាព ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | ល្អូខ | ម៉ូរ៉ា | អត្តលេខ ០១០៧២ | នាយការិយាល័យ |
| ២-វរសេនីយ៍ត្រី | ឈឹម | ភាព | អត្តលេខ ០៦២៦៣ | នាយរងការិយាល័យ |
| ៣-វរសេនីយ៍ទោ | សុខ | ចាន់ | អត្តលេខ ០៥៥៥៦ | នាយរងការិយាល័យ |
| ៤-វរសេនីយ៍ត្រី | តិត | តាំង | អត្តលេខ ០៧១០៨ | នាយរងការិយាល័យ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

| | | | | |
|---|---|---|---|---|
| ១-អនុសេនីយ៍ឯក | ចាន់ | ថន | អត្តលេខ ៣២៨២១ | នាយផ្នែក |
| ២-អនុសេនីយ៍ឯក | ម៉ង់ | ពៅ | អត្តលេខ ០២៦៦០ | នាយរងផ្នែក |
| ៣-អនុសេនីយ៍ឯក | គីម | យោធា | អត្តលេខ ៣២៤៧១ | នាយរងផ្នែក |
| ៤-អនុសេនីយ៍ត្រី | គីម | យោធិន | អត្តលេខ ០៦៣៥១ | នាយរងប៉ុស្តិ៍ |
| ៥-អនុសេនីយ៍ត្រី | ស្នេះ | មនោរម្យ | អត្តលេខ ៣២៤១៧ | មន្ត្រី |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល[illegible]ចាប់ពីថ្ងៃ[illegible]

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ ៨ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០០៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាស
# ស្តីពី
# ការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុ មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃ ទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើង ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ១**: ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងផ្នែកទី១៣.១ នៃជំពូកទី១៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះធ្វើសកម្មភាពសេដ្ឋកិច្ច ។ បុគ្គលទាំងឡាយ ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង សមាសភាពអ្នកទទួលបន្ទុកកិច្ចការពន្ធដារ ឬក្រោយពីមានការផ្ទេរ ឬការបញ្ឈប់អាជីវកម្ម ។

ពាក្យសុំចុះបញ្ជី និងលិខិតជូនដំណឹង ត្រូវអនុវត្តតាមទម្រង់លិខិតឯកភាព និងបែបបទកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។ ពាក្យសុំចុះបញ្ជីត្រូវមានភ្ជាប់ឯកសារ ដូចតទៅ៖

ក- ចំពោះសហគ្រាសនីតិបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ដែលបានបង់ពន្ធប្រថាប់ត្រា អមភ្ជាប់ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលជាអាទិ៍មាន៖ ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម លក្ខន្តិកៈសហគ្រាស ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម...។ល។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថតចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះ វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណផ្នែកសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនទ្រព្យ ក្រសួង ឬមន្ទីរ ទេសចរណ៍ ចំពោះសកម្មភាពអាជីវកម្ម សណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះសកម្មភាពអាជីវកម្មសាងសង់ជាដើម ។ល។

៤.វិញ្ញាបនបត្រចុះបញ្ជី របស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់) ។

៥.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង។

៦.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

ខ- ចំពោះសហគ្រាសឯកបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អមភ្ជាប់មកជាមួយច្បាប់ថតចម្លងសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីពាណិជ្ជកម្ម ។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថត

ចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដូចជា មន្ទីរទេសចរណ៍ ចំពោះសកម្មភាព អាជីវកម្មសណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះ សកម្មភាពអាជីវកម្មសាងសង់ ជាដើម ។ល។

៤.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង ។

៥.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

**ប្រការ២:** ដូចមានចែងក្នុងមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ហើយក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី ។

**ប្រការ៣:** ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានចាត់ទុកជាអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (ដែលត្រូវទទួលរងទោសទណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ) ក្នុងករណីដែល បុគ្គលមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ឬមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ពីការផ្លាស់ប្តូរផ្សេងៗ ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ៤:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាស នេះឱ្យបានល្អប្រសើរ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

<u>ចម្លងជូន:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី } "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់សាលារាជធានី-ខេត្ត }
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ពាក្យសុំចុះបញ្ជីពន្ធដារ

នាមត្រកូល និងនាមខ្លួន៖........................................................................... សញ្ជាតិ៖..........................................
អាសយដ្ឋានបច្ចុប្បន្ន៖...........................................................................................................................
អត្តសញ្ញាណប័ណ្ណ☐ លិខិតឆ្លងដែនលេខ☐.............................................ចុះថ្ងៃទី...........ខែ...........ឆ្នាំ...............
ក្នុងនាមជា៖ ស្ថាបនិក ☐ អភិបាល ☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
នៃ ក្រុមហ៊ុន☐ សហគ្រាស☐៖.........................................................................................................
Name of Enterprise: ..............................................................................................................

ខ្ញុំបាទ/នាងខ្ញុំ សុំចុះឈ្មោះ ក្រុមហ៊ុន សហគ្រាស ដូចមានឈ្មោះខាងលើ ក្នុងបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១. វិញ្ញាបនបត្រ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម☐
២. លិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម☐
៣. ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម៖
- ច្បាប់ថតចម្លងពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម☐
- ច្បាប់ថតចម្លងលក្ខន្តិកៈសហគ្រាស☐
- ច្បាប់ថតចម្លងពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម☐
- ច្បាប់ថតចម្លងលិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ☐
- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ☐ ឬ ច្បាប់ថតចម្លងលិខិតឆ្លងដែន(សម្រាប់ជនបរទេស)☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐និងរូបថត៤x៦ចំនួន០២សន្លឹក

៤. ច្បាប់ថតចម្លងសៀវភៅគ្រួសារ☐ ឬសៀវភៅស្នាក់នៅ☐ ឬច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ (សម្រាប់ជនបរទេស)ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
៥. លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម ចេញដោយស្ថាប័នមានសមត្ថកិច្ច☐
៦. វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា☐
៧. កិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម)☐ ភ្ជាប់ដោយលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង☐
៨. វិក្កយបត្រទឹក និងអគ្គិសនី (ច្បាប់ថតចម្លងរយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស☐
៩. ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ☐
១០. សលាកបត្រព័ត៌មានសហគ្រាស/ក្រុមហ៊ុន☐
១១. ពាក្យស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែម (សម្រាប់របបស្វ័យប្រកាស)☐
១២. លិខិតប្រកាសអាករលើផលរបរ និងពន្ធលើប្រាក់ចំណេញ "របបម៉ៅការ"☐
១៣. លិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំសម្រាប់របបម៉ៅការ☐ ឬរបបស្វ័យប្រកាស☐

ពាក្យសុំចុះបញ្ជីពន្ធដារនេះមានចំនួន...............ច្បាប់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................................................ឋានៈ/តួនាទី.......................................................នៃសហគ្រាស/ក្រុមហ៊ុនខាងលើសូមធានាថា ឯកសារ និងព័ត៌មានទាំងអស់ភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារនេះ ពិតជាត្រឹមត្រូវ ។ ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

ធ្វើនៅ........................, ថ្ងៃទី.............ខែ.............ឆ្នាំ.............

បានទទួលពាក្យសុំចុះបញ្ជី
ថ្ងៃទី............ខែ............ឆ្នាំ............
មន្ត្រីពន្ធដារ

*កំណត់សម្គាល់៖ សូមគូសសញ្ញា √ នៅក្នុងប្រអប់ចំពោះឯកសារដែលមានភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៩៩៧.១៩.៥...កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញកិច្ចសន្យាជួលទីតាំងដីមួយផ្នែកនៃអតីតរោងចក្រជីហ្វូសស្វាតភ្នំធំ ចុះថ្ងៃទី១១.១១.២០០៩ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន PHOSPHATE & CHEMICAL (CAMBODIA) Co., Ltd.
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វូសហ្វេត & ខេមីខល (ខេមបូឌា) ចុះថ្ងៃទី២៩.០៧.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វូសហ្វេត & ខេមីខល (ខេមបូឌា) តំណាងដោយ លោក POONPERM APICHITVITAYA សញ្ជាតិថៃ អាយុ៣០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S799261 ចុះថ្ងៃទី២១.០៨.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ No. 194 TANOW ROAD, SANGKAT BOWONNIVETH, KHAN PREANAKORN, BANGKOK 10200 ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រផលិតជី លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| ជីហ្វូស្វាត | ២០១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *"ហ្វូសហ្វេត & ខេមីខល (ខេមបូឌា) "*
*"(PHOSPHATE & CHEMICAL (CAMBODIA) Co., Ltd. )"*

**ទីតាំងរោងចក្រ៖** *"ភូមិត្នុំធំត្បូង ឃុំទួលប្រសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបន្ទាយមានជ័យ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**ស៊ុយ_សែម**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តបន្ទាយមានជ័យ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

លេខ : ៩៩៨ ឧរថ-គ.ឱ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២១១១ /១១ គ.វ.ក ចុះថ្ងៃទី១៥.០៩.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដលហ្វីន យ៉ាំ មេនូហ្វេកឈើរ ចុះថ្ងៃទី០៥.០៩.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ដលហ្វីន យ៉ាំ មេនូហ្វេកឈើរ តំណាងដោយ លោក NAGAKURA EIJI សញ្ជាតិជប៉ុន អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TH0940311 ចុះថ្ងៃទី១១.០៧.២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1-6-3 Yamato Shizuoka-City Zhizuoka, Japan ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code |
|---|---|
| កាបូប | ១៥១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" ដលហ្វីន យ៉ាំ មេនូហ្វេកឈ័រ "*
*"(DOLPHINS JUMP MANUFACTURE CO., LTD. )"*

**ទីតាំងរោងចក្រ ៖** *" សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ៨៥ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

